# របៀបកំណត់អត្ថប្រយោជន៍ការធានា រ៉ាប់រងភាពអត់ការងារធ្វើរបស់លោកអ្នក



### "អំឡុងពេលមូលដ្ឋានរបស់លោកអ្នក

«ចំនួនទឹកប្រាក់» នៃការទាមទារការធានារ៉ាប់រងភាពអត់ការងារធ្វើរបស់លោកអ្នក (UI)—ចំនួនទឹកប្រាក់ដែលលោកអ្នកប្រហែលជា អាចទទួលបាន តាមតម្រូវការសិទ្ធិទទួលបានទាំងអស់— ត្រូវបានកំណត់ដោយប្រាក់ចំណូលដែលបានបង់ជូនលោកអ្នកក្នុង អំឡុងពេលរហូតដល់ 52 សប្តាហ៍ដូចដែលបានកំណត់តាមច្បាប់រដ្ឋម៉ាស្សាឈូសេត។ នេះត្រូវបានរាប់ទុកថាជា «អំឡុងពេលមូលដ្ឋាន» របស់លោកអ្នក។

### របៀបកំណត់អំឡុងពេលមូលដ្ឋានរបស់លោកអ្នក

«អំឡុងពេលមូលដ្ឋានចម្បង»-- នោះអំឡុងពេលដែលរួមមាននូវសប្តាហ៍ ការងារ ដែលត្រូវបានប្រើប្រាស់ជាដំបូង ដើម្បីគណនាប្រាក់ធានារ៉ាប់រងភាពអត់ការងារធ្វើ – គឺជាត្រីមាសចុងក្រោយដែលបានបំពេញទាំងបួនភ្លាមៗបន្ទាប់ពី ថ្ងៃដែលការទាមទារប្រាក់របស់លោក អ្នកមានប្រសិទ្ធិភាព។ លោក អ្នកប្រហែលជាអាចយកការទាមទាររបស់អ្នកឲ្យសំអាងតាម «អំឡុងពេលមូលដ្ឋានជម្រើស» ស្ថិតក្រោមស្ថានភាពជាក់លាក់ដែលបានកំណត់ក្នុងច្បាប់បានផង ដែរ។

ក្នុងពេលដែលអំឡុងពេលមូលដ្ឋានជម្រើសត្រូវបានប្រើប្រាស់ការ ទាមទាររបស់លោកអ្នកត្រូវបានធ្វើឡើងផ្អែកតាមប្រាក់កម្រៃដែល នបង់ជូនអ្នក អំឡុងពេលត្រីមាសដែលបានបំពេញទាំងបីចុងក្រោយបំផុត បូកនឹងរយៈពេល នៃពេលវេលារវាងត្រីមាស ដែលបានបំពេញចុងក្រោយនិងថ្ងៃមានប្រសិទ្ធិភាពនៃការទាមទារ របស់អ្នក។ (សូមមើលតារាងនៅផ្នែកខាងក្រោមទំព័រនេះ។)

### ឆ្នាំអត្ថប្រយោជន៍របស់លោកអ្នក

ដើម្បីយល់អំពីដំណើរការនេះ គឺសំខាន់ណាស់ដើម្បីនឹងដឹងអំពីរបៀបកំណត់អត្ថប្រយោជន៍របស់ លោកអ្នក។ កាលណាការទាមទាររបស់លោកអ្នកបានស្ថាបនាហើយ «ឥណទានអត្ថប្រយោជន៍» គឺត្រូវបានគណនា។ ឥណទានអត្ថប្រយោជន៍គឺជា ចំនួនសរុបនៃអត្ថប្រយោជន៍ដែលលោកអ្នកអាចនឹង មានគុណសម្បត្តិដើម្បីនឹងទទួល ក្នុងអំឡុង «ឆ្នាំអត្ថប្រយោជន៍» របស់លោកអ្នក ប្រសិនបើលោកអ្នកមានលទ្ធិភាពចំពោះកិច្ចតម្រូវ គុណសម្បត្តិទាំងអស់នៃច្បាប់។

«ឆ្នាំអត្ថប្រយោជន៍» របស់លោកអ្នកគឺជា 52 សប្តាហ៍ពីថ្ងៃមានប្រសិទ្ធិភាពនៃ ការទាមទាររបស់លោកអ្នក។

«អត្រាអត្ថប្រយោជន៍»— ទឹកប្រាក់អត្ថប្រយោជន៍ប្រចាំសប្តាហ៍របស់លោកអ្នក— ក៏ត្រូវបានគណនាផងដែរ។ វាផ្អែកទៅលើប្រាក់កម្រៃប្រចាំសប្តាហ៍មធ្យមរបស់លោកអកនក អំឡុងពេលពីរត្រីមាសខ្ពស់បំផុត។ មកទល់ថ្ងៃទី 1 "ខែតុលា ឆ្នាំ 2023, អត្រាអត្ថប្រយោជន៍អតិបរិមាគឺ $1033"ក្នុងមួយសប្តាហ៍។

«អំឡុងពេលនៃអត្ថប្រយោជន៍» របស់លោកអ្នក— ចំនួនសប្តាហ៍អតិបរិមាដែលអ្នកមានសិទ្ធិទទួលបាន ដើម្បីទទួលអត្ថប្រយោជន៍ – ត្រូវបានកំណត់ដោយការចែកអត្រាអត្ថប្រយោជន៍របស់លោកអ្នក ជាមួយនឹងឥណទានអត្ថប្រយោជន៍។ ចំនួនសប្តាហ៍អតិបរមាដែលអ្នកទាមទារអាច ទទួលបានអត្ថប្រយោជន៍ UI ជាធម្មតា 30 សប្តាហ៍ (បិទគ្របត្រង់ 26 សប្តាហ៍ក្នុងអំឡុងពេលនៃអត្ថប្រយោជន៍ បន្តបន្ថែម)។ ព័ត៌មានអំពីសិទ្ធិទទួលបានជាប្រាក់កាសរបស់លោកអ្នក— ចំនួនទឹកប្រាក់ សរុបនៃអត្ថប្រយោជន៍ដែលលោកអ្នកប្រហែលជាអាចមានសិទ្ធិទទួល ប្រសិនបលោក អ្នកបំពេញរាល់តម្រូវការសិទ្ធិទទួលបានទាំងអស់— នឹងត្រូវបានផ្ញើជូនលោកអ្នក ឬអាចយកបានតាមរយៈអនឡាញ។

### របៀបកំណត់ប្រាក់កម្រៃនៃអំឡុងពេលមូលដ្ឋានរបស់លោកអ្នក

បណ្ដានិយោជកនៅរដ្ឋម៉ាស្សាឈូសិត ត្រូវបានតម្រូវឲ្យរាយការណ៍ពត៌មានពីប្រាក់កម្រៃទៅកាន់ក្រសួងប្រា ក់ចំណូលរបស់រដ្ឋ មិនឲ្យយឺតជាង 30 ថ្ងៃបន្ទាប់ពីការបិទត្រីមាសនីមួយៗ។ នេះមានន័យថា ប្រាក់កម្រៃត្រូវបានរាយការណ៍នៅក្នុងខែមេសា កក្កដា តុលា និងមករា។ ព័ត៌មានពីកម្រៃត្រូវបានប្រើប្រាស់ដើម្បីកំណតើសិទ្ធិទទួលបានអត្ថ ប្រយោជន៍"UI"ជាទឹកប្រាក់ដែលអាចមានរបស់លោកអ្នក។ នៅពេលដែល «រយៈពេលមូលដ្ឋានចម្បង» ត្រូវបានប្រើប្រាសើអត្ថប្រយោជន៍ផ្អែកលើកប្រាក់កម្រៃដែលបានបង់ នៅក្នុងត្រីមាសដែលបានបំពេញទាំងបួនចុងក្រោយ។

# របៀបកំណត់អត្ថប្រយោជន៍ការធានា រ៉ាប់រងភាពអត់ការងារធ្វើរបស់លោកអ្នក

តាមតារាងខាងក្រោម លោកអ្នកអាចមើលឃើញប្រាក់កម្រៃនាពេលថ្មីៗត្រឹមត្រូវនឹងត្រូវបានប្រើប្រាស់ ប្រសិនបើអ្នកដាក់ពាក្យទាមទាមរនាដើមត្រីមាស។ នៅពេលអ្នកដាក់ពាក្យទាមទាររបស់អ្នកនៅចុងត្រីមាស ប្រាក់កម្រៃនឹងដែលបានប្រើប្រាស់ដើម្បីកំណត់ការទាមទាររបស់លោកអ្នក នឹងមិនត្រូវបង្ហាញពីការកើនឡើងនាពេលថ្មីៗបំផុតក្នុងប្រាក់ចំណូលរបស់អ្នក។

| ប្រសិនការទាមទាររបស់លោកអ្នកមានប្រសិទ្ធិភាពក្នុង: | អត្ថប្រយោជន៍របស់លោកអ្នកគឺសំអាងទៅលើប្រាក់កម្រៃដែលបានបង់ជូន: | |
|---|---|---|
| | ពី: | រហូតដល់: |
| ខែមករា, ខែកុម្ភៈ, ឬខែមិនា | ថ្ងៃទី 1 ខែមករា ឆ្នាំមុន | ថ្ងៃទី 31 ខែធ្នូ ឆ្នាំនេះ |
| ខែមេសា, ខែឧសភា, ឬខែមិថុនា | ថ្ងៃទី 1 ខែមេសា ឆ្នាំមុន | ថ្ងៃទី 31 ខែមិនា ឆ្នាំនេះ |
| ខែកក្កដា, ខែសីហា, ឬខែកញ្ញា | ថ្ងៃទី 1 ខែកក្កដា ឆ្នាំមុន | ថ្ងៃទី 30 ខែមិថុនា ឆ្នាំនេះ |
| ខែតុលា, ខែវិច្ឆិកា, ឬខែធ្នូ | ថ្ងៃទី 1 ខែតុលា ឆ្នាំមុន | ថ្ងៃទី 30 ខែកញ្ញា ឆ្នាំនេះ |

## ការយល់ដឹងអំពីអំឡុងពេលមូលដ្ឋាន

ប្រសិនបើលោកអ្នកពុំមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ដោយប្រើប្រាស់អំឡុងពេលមូលដ្ឋានចម្បង ហើយនិងមានសិទ្ធិទទួលបានដោយប្រើប្រាស់អំឡុងពេលមូលដ្ឋានជម្រើសនោះ DUA នឹងប្រើប្រាស់វិធីសាស្ត្រនេះដោយស្វ័យប្រវត្តិ ដើម្បីកំណត់អត្ថប្រយោជន៍របស់លោកអ្នក។

នៅពេលដែលអំឡុងពេលមូដ្ឋានជម្រើសត្រូវបានប្រើប្រាស់ ការទាមទាររបស់អ្នកនឹងត្រូវបានធ្វើឡើងផ្អែកតាមប្រាក់កម្រៃដែលបានបង់ជូនលោកអ្នក អំឡុងពេលបីត្រីមាស ដែលបានបំពេញចុងក្រោយបំផុត ឬក៏ពេលវេលារវាងត្រីមាស ដែលបានបំពេញចុងក្រោយ និងថ្ងៃមានប្រសិទ្ធិភាពនៃការទាមទាររបស់លោកអ្នក។"ខាងក្រោមនេះគឺជាឧទាហរណ៍:

| ការទាមទារមានប្រសិទ្ធិភាពនៅថ្ងៃទី: | អត្ថប្រយោជន៍សំអាតតាមប្រាក់កម្រៃដែលបានបង់: """"" | |
|---|---|---|
| | ពី: | រហូតដល់: |
| **ថ្ងៃទី 5 ខែវិច្ឆិកា, ឆ្នាំ 2023** | **ថ្ងៃទី 1 ខែមករា, ឆ្នាំ 2023** | **ថ្ងៃទី 4 ខែវិច្ឆិកា, ឆ្នាំ 2023** |
| **ថ្ងៃទី 7 ខែមករា, ឆ្នាំ 2023** | **ថ្ងៃទី 1 ខែមេសា, ឆ្នាំ 2023** | **ថ្ងៃទី 6 ខែមករា, ឆ្នាំ 2024** |
| **ថ្ងៃទី 7 ខែមេសា, ឆ្នាំ 2024** | **ថ្ងៃទី 1 ខែកក្កដា, ឆ្នាំ 2023** | **ថ្ងៃទី 6 ខែមេសា, ឆ្នាំ 2024** |
| **ថ្ងៃទី 7 ខែកក្កដា, ឆ្នាំ 2024** | **ថ្ងៃទី 1 ខែតុលា, ឆ្នាំ 2023** | **ថ្ងៃទ 6 ខែកក្កដា, ឆ្នាំ, 2024** |
| **ថ្ងៃទី 6 ខែតុលា, ឆ្នាំ 2024** | **ថ្ងៃទី 1 ខែមករា, ឆ្នាំ 2024** | **ថ្ងៃទី 5 ខែតុលា, ឆ្នាំ, 2024** |

## នៅពេលណាលោកអ្នកអាចជ្រើសរើសវិធីសាស្ត្រជម្រើស

នៅក្រោមស្ថានភាពជាក់លាក់ក្រៃលែងដែលកំណត់នៅក្នុងច្បាប់ អ្នកទាមទារអាចជ្រើសរើសធ្វើការទាមទាររបស់ខ្លួនដោយប្រើប្រាស់វិធីសាស្ត្រជម្រើស ទោះបីជាពួកគេមានសិទ្ធិទទួលបានអត្ថប្រយោជន៍មួយចំនួនស្ថិតក្រោមអំឡុងពេលមូលដ្ឋានចម្បងក៏ដោយ។

លោកអ្នកប្រហែលអាចមានសិទ្ធិទទួលបានជម្រើសនេះ លើកលែងតែ:

- ការទាមទាររបស់លោកអ្នកត្រូវបានធ្វើឡើងដោយប្រើប្រាស់ "អំឡុងពេលមូលដ្ឋានចម្បង។"
- លោកអ្នកអាចផ្ដល់ជាចំពោះ DUA នូវ "ភស្តុតាងជាក់ច្បាស់"" នៅក្នុងអក្សរលាយលក្ខណ៍ (ដែលអាចមានរួម ប៉ុន្តែពុំមានកំហិតចំពោះ តុល្យបញ្ជីប្រាក់កម្រៃ)ដែលឥណទានអត្ថប្រយោជន៍សរុប អាចបង់ឲ្យដល់លោកអ្នក ដោយការប្រើ "អំឡុងពេលមូលដ្ឋានជម្រើស"" ដែលមានយ៉ាងហោចណាស់ 10" ភាគរយច្រើនជាងចំនួនអត្ថប្រយោជន៍ឥណទានសរុប ដោយការប្រើវិធីសាស្ត្រចម្បង។
- លោកអ្នកពុំមានលទ្ធិភាពចំពោះជម្រើសនេះ ប្រសិនបើ:
- ការទាមទាររបស់លោកអ្នកបានស្ថាបនារួចហើយដោយការប្រើប្រាស់ "អំឡុងពេលមូលដ្ឋានជម្រើស ។"

## ប្រសិនបើលោកអ្នកមិនយល់ព្រមនឹងប្រាក់កម្រៃដែលបានរាយការណ៍

ប្រសិនបើលោកអ្នកមិនយល់ព្រមនឹងចំនួនដែលបានរាយការណ៍ចំពោះ DUA"ទេ, សូមទូរស័ព្ទទៅមជ្ឈមណ្ឌល the TeleClaim Center. DUA នឹងស្នើរសុំលោកអ្នកឲ្យផ្ដល់ភស្តុតាងនៃចំនួនប្រាក់កម្រៃដែលលោកអ្នកកំពុងតែតវ៉ា រួចហើយស្នើរសុំនូវការបញ្ជាក់នៃព័ត៌មានប្រាក់កម្រៃដោយផ្ទាល់ពីនិយោជករបស់លោកអ្នក។

ប្រសិនសិនបើត្រូវបានសម្រេចថាលោកអ្នកពុំមានប្រាក់កម្រៃគ្រប់គ្រាន់ នៅក្នុងអំឡុងពេលមូលដ្ឋានចម្បងឬជម្រើស ដើម្បីនឹងស្ថាបនាការទាមទារ ឬប្រសិនសិនបើលោកអ្នកបន្តមិនយល់ព្រមចំពោះចំនួនប្រាក់កម្រៃបានរាយការណ៍ទេ លោកអ្នកមានសិទ្ធិដើម្បីនឹងដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ដើម្បីនឹងមាននូវសវនាការ។

ប្រសិនបើលោកអ្នកមានសំណួរថែមទៀត សូមសួរអ្នកតំណាង។